# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អធិប្បាយពាក្យថា ការធ្វើបុណ្យកុសលជាតិនេះ ពុំមែនជាផលនៃជាតិក្រោយទេ និងអ្នកដែលមានបុណ្យសក្តិនិងទ្រព្យសម្បត្តិជាតិនេះ ក៏ពុំមែនកើតឡើងតែពីបុណ្យជាតិមុនតែម៉្យាងដែរ ។

web site: hoksavann.org

ថ្ងៃទី៥ កុម្ភៈ ២០០៥

អ្នកដែលសិក្សាព្រះពុទ្ធសាសនាតិចច្រើនយល់ច្រឡំថា ការធ្វើបុណ្យកុសលជាតិនេះសំរាប់ទទួលផលជាតិក្រោយ ។ ការយល់នេះត្រូវបានមួយភាគពុំត្រឹមត្រូវទាំងអស់ទេ ។ បុណ្យកុសលដែលគេធ្វើរមែងឲ្យផលតាំងពីជាតិនេះទៅ ដូចជាអនិសង្សក្នុងការធ្វើទានរមែងមានគេស្រឡាញ់គេរាប់អានច្រើនកេរ្តិ៍ឈ្មោះល្អរមែងផ្សាយទៅក៏ដូចជាការរក្សាសីល រមែងគេស្រឡាញ់គេទុកចិត្តសប្បុរសតែងយកជាមិត្ត ទៅទីណាកន្លែងណាតែងមានសេចក្តីក្លាហាន មិនសំយុងមុខចុះដោយសារខ្លួនជាអ្នកមានសីល ពុំបៀតបៀនអ្នកដទៃដែលនាំឲ្យមានសត្រូវជាដើម នេះជាផលដែលបានទទួលក្នុងបច្ចុប្បន្នពុំមែនចាំជាតិក្រោយឡើយ ។ ក្នុងព្រះពុទ្ធសាសនាបានពោលថា កម្មកុសលនិងអកុសលខ្លះឲ្យផលតាមទម្ងន់ គឺអំពើល្អនិងអំពើអាក្រក់ធ្ងន់ត្រូវឲ្យផលមុន ឯកម្មស្រាលត្រូវឲ្យផលក្រោយ; កម្មខ្លះត្រូវឲ្យផលក្នុងពេលប្រព្រឹត្តធ្វើ; កម្មខ្លះត្រូវឲ្យផលពុំទៀងជាពេលណាត្រូវឲ្យផលប្រៀបដូចជាឆ្កែដេញទន្សាយជួបពេលណាចាប់ខាំពេលនោះ មានកម្មខ្លះពុំអាចឲ្យផលបាន ដោយសារមានកម្មមួយផ្សេងពីនោះឲ្យផលកាត់មុខ ។ កម្មខ្លះឲ្យផលជាតិនេះឬជាតិខាងមុខជាបន្តៗទៅទៀត ។ ពុទ្ធសាសនាពោលថា បានជាកម្មឲ្យផលពុំទៀង ព្រោះមនុស្សបុថុជ្ជនធ្វើកម្មពុំទៀងដែរ ម្តងធ្វើល្អម្តងធ្វើអាក្រក់ ។ ផ្ទុយគ្នាពីមគ្គផលរបស់ព្រះអរិយបុគ្គល គឺបើមគ្គកើតឡើង ផលក៏កើតឡើងក្នុងលំដាប់គ្នាដោយគ្មានកម្មណាមួយឲ្យផលជាតិខាងមុខឡើយ ។ បានសេចក្តីថា បើសោតាបត្តិមគ្គកើតឡើងអរហត្តផលក៏កើតឡើង ។ អំពើល្អក្តីអាក្រក់ក្តី មិនថាតែអំពើមានទម្ងន់ធ្ងន់ទេ ទោះបីអំពើមានទម្ងន់ស្រាលក៏ត្រូវតែតាមឲ្យផល ប្រៀបដូចស្រមោលអន្ទោលតាមប្រាណ ។ ពុទ្ធសាសនាពោលទៀតថា មត៌ករបស់មនុស្សសត្វពិតប្រាកដ គឺកម្មល្អកម្មអាក្រក់នេះឯង (កម្មទាយាទោ) ។ អំពើមួយត្រូវចេញជាផលមួយ ពុំមែនអំពើណាមួយគ្មានចេញផលនោះឡើយ ក៏ដូចជាហេតុមួយត្រូវចេញផលមួយដូចគ្នាដែរ នេះជាហេតុផលតាមច្បាប់ធម្មជាតិ ។ ដូច្នេះ អ្នកដែលពោលថា ធ្វើបុណ្យមានការធ្វើទានរក្សាសីលអប់រំចិត្តជាដើម ចាំទទួលផលនៅជាតិខាងមុខនោះ សូមប្រែការយល់និងពោលដូច្នេះវិញថា ធ្វើបុណ្យកុសលដើម្បីសាងខ្លួនឲ្យល្អ ដើម្បីសុខចំរើនក្នុងជាតិនេះនិងជាតិខាងមុខ ទើបត្រឹមត្រូវតាមន័យរបស់ព្រះពុទ្ធសាសនា ។

បញ្ហាមួយទៀត គេមិនត្រូវយល់និងនិយាយតែមួយផ្នែកថា អ្នកដែលបានបុណ្យសក្តិនិងមានទ្រព្យសម្បត្តិច្រើនដោយសារបុណ្យពីជាតិមុននោះឡើយ ។ ដើម្បីយល់និងនិយាយឲ្យត្រឹមត្រូវតាមន័យរបស់ព្រះពុទ្ធសាសនា គេត្រូវនិយាយថា អ្នកដែលបានបុណ្យស័ក្តិនិងមានទ្រព្យសម្បត្តិច្រើនក្នុងជាតិនេះ ដោយសារបុណ្យពីជាតិមុនផ្សំគ្នានឹងការខំប្រឹងប្រែងសិក្សារៀនសូត្រនិងធ្វើការងារល្អក្នុងជាតិនេះផង ។ បានសេចក្តីថា មានឧបនិស្ស័យដោយបានសាងល្អពីជាតិមុនផង ហើយក្នុងជាតិនេះបានខំព្យាយាមសាងល្អទៀត ផ្សំគ្នាទើបកើតបានជាលទ្ធផលល្អបែបនេះ ។ ត្រង់ន័យនេះ ស្របនឹងពាក្យនៅក្នុងមង្គលសូត្រថា ភាពនៃបុគ្គលដែលបានធ្វើបុណ្យពីជាតិមុន និងការដំកល់ខ្លួនដោយប្រពៃក្នុងបច្ចុប្បន្ន ចាត់ទុកជាមង្គលដ៏ឧត្តម ។ ស្របនឹងពាក្យខ្មែរថា ព្រេងនិងប្រឹងជាគូគ្នា ។ បានសេចក្តីថា បើមានព្រេងវាសនាឬមានសំណាង ដោយបានកសាងពីជាតិមុនក៏ដោយ បើមិនបានខំប្រឹងប្រែងព្យាយាមក្នុងផ្លូវល្អក្នុងជាតិនេះទៀតទេ ព្រេងវាសនានោះពុំអាចកើតឡើងឡើយ ។ ប្រៀបដូចជាព្រេងមាននៅក្នុងល្ងឬនៅក្នុងដូងទុំ បើមិនយកល្ងឬដូងនោះមករំងាស់ឲ្យចេញជាប្រេងទេ ប្រេងពុំអាចកើតឡើងបានឡើយ ។ ដូចបុគ្គលមានគ្រាប់ពូជ បើពុំយកគ្រាប់ពូជនោះ ទៅបណ្តុះដាំដោយដាំលើដីល្អមានជីរជាតិមានពន្លឺទេ គ្រាប់ពូជនោះពុំអាចដុះជាដើមបែកជាមែកបញ្ចេញជាផ្លែផ្កាបានឡើយ ។ យ៉ាងណាមិញគ្រាប់ពូជប្រៀបដូចបុណ្យពីជាតិមុន ការយកទៅដាំប្រៀបដូចជាការងារល្អក្នុងបច្ចុប្បន្ននេះ ។ អំពើល្អពីអតីតជាតិផង អំពើល្អក្នុងបច្ចុប្បន្នផង ទើបបុណ្យស័ក្តិនិងទ្រព្យនោះបានមកប្រកបដោយធម៌ ។ ប៉ុន្តែបើបុណ្យស័ក្តិនិងទ្រព្យសម្បត្តិបានមកដោយអំពើទុច្ចរិត ដូចជាចំណេះវិជ្ជាតិចលើកឲ្យធ្វើធំដោយសារបក្សពួកនិងទ្រព្យសម្បត្តិបានមកដោយអំពើពុករលួយលក់ជាតិកេងប្រវ័ញ្ចប្រជាពលរដ្ឋ បុណ្យស័ក្តិនិងទ្រព្យសម្បត្តិនោះពុំមែនកើតឡើងដោយបុណ្យពីជាតិមុនឡើយ តែដោយអំពើទុច្ចរិត ហើយរបស់ដែលបានមិនប្រកបដោយធម៌នោះ នឹងត្រូវវិនាសទៅវិញក្នុងពេលណាមួយពុំខានឡើយ ។៚